ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ
យុវជន និងកីឡា

# គោលនយោបាយ ស្តីពីសៀវភៅសិក្សា

## និង

## មគ្គុទេសក៍សម្រាប់ ការអភិវឌ្ឍសៀវភៅសិក្សាគោល

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
ឆ្នាំ ២០១២

ADB ឧបត្ថម្ភដោយ គម្រោងលើកកម្ពស់គុណភាពអប់រំ
EEQP/ADB Grant No.0090 CAM (SF)

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយស្តីពី
# សៀវភៅសិក្សា

## និង

## មគ្គុទ្ទេសក៍សម្រាប់ការអភិវឌ្ឍ
## សៀវភៅសិក្សាគោល

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
ឆ្នាំ២០១២

## គណៈកម្មការគ្រប់គ្រង

ឯកឧត្តម កើ ណៃណាង | ឯកឧត្តម អ៊ូ អេង

លោកជំទាវ ទន់ សាអ៊ីម | លោក អេង គឹមលី

## គណៈកម្មការរៀបចំ

លោក ស៊ុន ប៊ុណ្ណា | លោក ឃឹម សារិន

លោក ព្រំ តារិទ្ធ | លោក លឹម សុត្ថារិទ្ធ

## គណៈកម្មការត្រួតពិនិត្យ

លោក អេង គឹមលី | លោក សុខ ឫទ្ធី

## ជំនួយការបច្ចេកទេស

លោក ប៊ែរី ឃុក ( Barry Cook )

## រចនា និងវាយកុំព្យូទ័រ

លោក លឹម សុត្ថារិទ្ធ | កញ្ញា មឿង ច័ន្ទផល្លី

# កថាមុខ

វិស័យអប់រំ ជាវិស័យគន្លឹះមួយរួមចំណែកយ៉ាងខ្លាំងក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ពិសេសការអភិវឌ្ឍធនធានមនុស្ស។ ដោយសង្គមមានការអភិវឌ្ឍលើគ្រប់វិស័យ ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់ជាចម្បងក្នុងការអភិវឌ្ឍ និងផ្គត់ផ្គង់សៀវភៅសិក្សាគោល ព្រមទាំងឯកសារអំណានផ្សេងៗ ដែលបម្រើឱ្យការអប់រំនៅតាមសាលារៀនចំណេះទូទៅ ដើម្បីលើកកម្ពស់គុណភាពអប់រំនៅកម្រិតអប់រំមូលដ្ឋាន និងមធ្យមសិក្សាទុតិយភូមិប្រកបដោយចីរភាព។

ផ្អែកលើគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ និងអនុវត្តតាមផែនការផ្គត់ផ្គង់សៀវភៅសិក្សាគោលដល់សិស្សដោយឥតគិតថ្លៃតាមអត្រាផលធៀបសៀវភៅ និងសិស្ស គឺ១:១នៅកម្រិតអប់រំមូលដ្ឋាន និង ១:២នៅមធ្យមសិក្សាទុតិយភូមិ។ ដោយឡែកក្រសួងនៅតែបន្តអនុវត្តអត្រាថេរ១:១សម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិនៅខេត្តដាច់ស្រយាល។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាសហការជាមួយគម្រោងលើកកម្ពស់គុណភាពអប់រំ ( EEQP/ADB Grant No. 0090 CAM ( SF ) ) បានអភិវឌ្ឍឯកសារ ***គោលនយោបាយស្ដីពីការអភិវឌ្ឍសៀវភៅសិក្សា និងមគ្គុទ្ទេសក៍សម្រាប់ការអភិវឌ្ឍសៀវភៅសិក្សាគោល*** ឡើងដើម្បីធានាឱ្យបានការផ្គត់ផ្គង់ប្រកបដោយចីរភាព និងសម្បូរបែប ព្រមទាំងផ្ដល់ឱកាសដល់វិស័យឯកជនចូលរួមប្រកួតប្រជែង និងវិនិយោគក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល និងឯកសារផ្សេងៗបម្រើដល់ការអប់រំនៅកម្ពុជា។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមថ្លែងអំណរគុណចំពោះគម្រោងលើកកម្ពស់គុណភាពអប់រំ និងក្រុមការងារនៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដែលបានខិតខំអភិវឌ្ឍឯកសារដ៏មានតម្លៃនេះ ដើម្បីលើកកម្ពស់ការអភិវឌ្ឍ និងផ្គត់ផ្គង់សៀវភៅសិក្សាគោលឱ្យមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែ [illegible] ឆ្នាំ២០១២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អនុរដ្ឋលេខាធិការ**

**កើ_ណៃណាង**

# គោលនយោបាយ
# ស្ដីពី
# សៀវភៅសិក្សា

# មាតិកា

ទំព័រ


១. សាវតារ ........................................................................ ៣

២. គោលបំណង និងវត្ថុបំណងនៃការផ្គត់ផ្គង់សៀវភៅសិក្សា..... ៦

៣. នីតិវិធីដើម្បីសម្រេចបាននូវវត្ថុបំណងទី១: លទ្ធភាព ដើម្បីទទួលបានសៀវភៅសិក្សា ........................................... ៧

៤. នីតិវិធីដើម្បីសម្រេចបាននូវវត្ថុបំណងទី២: គុណភាព នៃសៀវភៅសិក្សា ............................................................ ១១

៥. នីតិវិធីដើម្បីសម្រេចបាននូវវត្ថុបំណងទី៣: ការគាំទ្រ សម្រាប់សៀវភៅសិក្សា ..................................................... ១៤




# ១. សាវតារ

## ក. សារៈសំខាន់នៃសៀវភៅសិក្សាគោលសម្រាប់ប្រទេសកម្ពុជា

ការអប់រំនៅប្រទេសកម្ពុជាមានការខ្វះខាតគ្រូបង្រៀនដែលទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់លើវិធីសាស្ត្របង្រៀនថ្មីដែលសង្កត់ធ្ងន់ទៅលើការរៀនបែបសកម្ម។ គ្រូបង្រៀនច្រើនតែមានទំនោរផ្តោតការសង្កត់ធ្ងន់លើការទន្ទេញចាំមាត់ ហើយជាលទ្ធផលសិស្សានុសិស្សច្រើនតែគ្មានសមត្ថភាពអាចផ្សារភ្ជាប់អ្វីដែលខ្លួនបានសិក្សាទៅនឹងការដោះស្រាយបញ្ហាប្រចាំថ្ងៃរបស់ខ្លួនបានឡើយ។ កុមារប្រហែលជាដឹងអំពីព័ត៌មានផ្សេងៗ ប៉ុន្តែជារឿយៗពួកគេមិនយល់អំពីព័ត៌មានទាំងអស់នោះ ឬមិនដឹងអំពីរបៀបប្រើប្រាស់ព័ត៌មានទាំងអស់នោះយ៉ាងដូចម្តេចនោះទេ។ ការផ្លាស់ប្តូរស្ថានភាពនេះ គឺជាបញ្ហាប្រឈមរយៈពេលវែងដែលទាមទារការកែលម្អឡើងវិញនូវកម្មវិធីសិក្សា ការបណ្តុះបណ្តាលគ្រូបង្រៀន និងបុគ្គលិកនៅក្នុងស្ថាប័នបណ្តុះបណ្តាល និងវិក្រឹតការនាពេលបច្ចុប្បន្ន។

អន្តរាគមន៍មួយដែលអាចនាំមកនូវការផ្លាស់ប្តូរដ៏ធំធេងគួរឱ្យកត់សម្គាល់ដោយប្រើប្រាស់ពេលវេលាខ្លីសមគួរនោះ គឺសាលារៀនត្រូវមានសៀវភៅសិក្សាគោលដែលលើកកម្ពស់វិធីសាស្ត្របង្រៀន និងវិធីរៀនថ្មី។ ប្រសិនបើអាចមានសៀវភៅសិក្សាបែបនេះយ៉ាងទូលំទូលាយនោះ សៀវភៅទាំងនេះនឹងអាចជួយសម្រួលគ្រូបង្រៀន តាមរយៈការផ្តល់ឧទាហរណ៍ស្តីពីវិធីសាស្ត្របង្រៀនថ្មី ព្រមទាំងអនុញ្ញាតឱ្យសិស្សានុសិស្សអាចធ្វើអន្តរកម្មជាមួយព័ត៌មានបានបើទោះបីជាគុណភាពនៃការបង្រៀននៅមានកម្រិតក៏ដោយ។

បញ្ហាប្រឈមសម្រាប់ប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជា គឺការធ្វើយ៉ាងណាដើម្បីផលិត និងចែកចាយសៀវភៅសិក្សាគោលដែលមានគុណភាពខ្ពស់

ក្នុងចំនួនគ្រប់គ្រាន់ដែលឆ្លុះបញ្ចាំងនូវវិធីសាស្រ្តបង្រៀន និងវិធីសាស្រ្តរៀនបែបថ្មីៗបញ្ហាប្រឈមនេះត្រូវបានគ្រប់គ្រងយ៉ាងល្អបំផុតនៅក្នុងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដែលធ្វើការក្នុងកិច្ចសហការជាមួយផ្នែកស្តង់ដារ និងការប្រឡង (Standard and Examination Division)។ ការគាំទ្រផ្នែកថវិកាសម្រាប់កំណើនចំនួនសៀវភៅសិក្សាពិតជាត្រូវការជាចាំបាច់។

## ខ. ការផ្តល់សៀវភៅសិក្សា

បច្ចុប្បន្ននេះសៀវភៅសិក្សាគោលសម្រាប់សិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូ គឺជាមធ្យោបាយដ៏ចម្បងសម្រាប់គាំទ្រដល់ការបង្រៀន និងរៀននៅតាមសាលារៀនក្នុងប្រទេសកម្ពុជា។នៅពេលអនាគតអាចនឹងមានមធ្យោបាយផ្តល់ការគាំទ្រផ្សេងទៀត ដូចជាការបញ្ជូនព័ត៌មានតាមរយៈប្រព័ន្ធអ៊ីនធើណិតជាដើម។ ប៉ុន្តែសម្រាប់រយៈពេលមធ្យមយើងគួរតែផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការធ្វើយ៉ាងណាដើម្បីអាចសម្រេចឱ្យបាននូវអត្រា១:១ គឺសៀវភៅសិក្សាគោលមួយក្បាលគ្រប់មុខវិជ្ជាសម្រាប់សិស្សម្នាក់ ចាប់ពីថ្នាក់ទី១ដល់ថ្នាក់ទី១២។ ជាជំហានដំបូង គួរផ្តោតការយកចិត្តទុកដាក់លើការធ្វើយ៉ាងណាដើម្បីសម្រេចឱ្យបាននូវអត្រា១:១នៅថ្នាក់ទី១ដល់ថ្នាក់ទី៩និងក្រោយមកនៅពេលដែលមានមូលនិធិយើងនឹងធ្វើសម្រាប់ថ្នាក់ទី១០ដល់ទី១២ ទៀត។ សម្រាប់រយៈពេលវែង និងនៅពេលដែលមានការអនុញ្ញាតពីរាជរដ្ឋាភិបាល និងមានថវិកាគ្រប់គ្រាន់ ក្រសួងអប់រំ យុវជន និងកីឡាគួរតែធ្វើឱ្យមានសម្ភារឧបទេសបន្ថែមក្នុងទម្រង់ជាសៀវភៅអានបន្ថែម សៀវភៅលំហាត់ និងសម្ភារឧបទេសផ្សេងទៀត។ល។



គោលនយោបាយស្តីពីសៀវភៅសិក្សា

## គ. ការបោះពុម្ពផ្សាយសៀវភៅសិក្សាគោល

បច្ចុប្បន្នសៀវភៅសិក្សាគោលទាំងអស់ត្រូវបានអភិវឌ្ឍដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយដែលជាសហគ្រាសស្វយ័តរបស់រដ្ឋនៅឡើយ។ នៅពេលអនាគតយើងរំពឹងថា នឹងមានការប្រកួតប្រជែងអភិវឌ្ឍសៀវភៅសិក្សាគោលដោយសហគ្រាសបោះពុម្ព និងចែកផ្សាយផ្សេងៗទៀតដែលនឹងធ្វើឱ្យមានសៀវភៅសិក្សាគោលកាន់តែច្រើននិងសម្បូរបែបសម្រាប់ការជ្រើសរើសរបស់សាលារៀន គ្រូបង្រៀន និងមាតាបិតាសិស្ស។

## ឃ. កម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការប្រឡង

សៀវភៅសិក្សាគោលសម្រាប់សិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូ ព្រមទាំងប្រព័ន្ធប្រឡងគួរតែឆ្លុះបញ្ចាំង និងគាំទ្រចំពោះវត្ថុបំណងរបស់កម្មវិធីសិក្សានាពេលបច្ចុប្បន្ន។ ហេតុនេះ ការសំខាន់អ្នកអភិវឌ្ឍសៀវភៅសិក្សាគោល អ្នកអភិវឌ្ឍកម្មវិធីសិក្សា និងមន្រ្តីទទួលបន្ទុកការប្រឡងត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នាក្រោមរចនាសម្ព័ន្ធគ្រប់គ្រងដែលស៊ីសង្វាក់ និងប្រាកដនិយម នៅក្រោមនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។ ដើម្បីសម្រេចបាននូវភាពស៊ីសង្វាក់គ្នារវាងកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការប្រឡង ដំណើរការនៃការអភិវឌ្ឍទាំងមូល រួមទាំងការអនុម័តឱ្យប្រើប្រាស់នៅក្នុងសាលារៀនផងដែរ ចាំបាច់ត្រូវតែស្ថិតក្នុងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាតែមួយ។ ការផ្តល់សិទ្ធិក្នុងការអនុម័តឱ្យប្រើប្រាស់សៀវភៅសិក្សា និងឯកសារសិក្សាស្ថិតនៅក្នុងគណៈកម្មាធិការដែលនៅខាងក្រៅ ដូចអ្វីដែលកំពុងធ្វើបច្ចុប្បន្ននេះ មានតម្លៃតិចតួចណាស់។ ការតម្រូវឱ្យអ្នកខាងក្រៅជាអ្នកអនុម័តនាំឱ្យមានការពន្យារពេលដែលមិនសមស្រប ក្នុងដំណើរការនាំយកសៀវភៅទៅកាន់សាលារៀន។

### ង. សៀវភៅសិក្សា និងការរៀនបែបសកម្ម

សៀវភៅសិក្សាគោលសម្រាប់សិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូ គប្បីឆ្លុះបញ្ចាំងនូវគោលបំណងរបស់កម្មវិធីសិក្សាក្នុងការលើកទឹកចិត្ត ការរៀនបែបសកម្ម ដើម្បីគាំទ្រដល់លទ្ធផលការសិក្សាឱ្យកាន់តែប្រសើរឡើង។ ស្ថាប័នអភិវឌ្ឍកម្មវិធីសិក្សា ស្ថាប័នអភិវឌ្ឍសៀវភៅសិក្សា និងស្ថាប័នបណ្ដុះបណ្ដាលគ្រូគួរតែបន្តផ្ដល់ការជួយជ្រោមជ្រែងដល់គ្រូបង្រៀនដើម្បីឱ្យពួកគាត់អាចកែប្រែការអនុវត្តនៅក្នុងថ្នាក់រៀនរបស់ពួកគាត់ ឆ្ពោះទៅការធ្វើឱ្យសិស្សានុសិស្សរៀនសូត្រដោយសកម្ម។

### ច. ការគ្រប់គ្រងគុណភាព

ស្ដង់ដារការបង្រៀន និងការវាយតម្លៃត្រូវបានបង្កើតឡើងរួចហើយ ហើយត្រូវបានយកមកអនុវត្តជាបណ្ដើរៗនៅក្នុងវិស័យទាំងមូល។ សៀវភៅសិក្សាគោល និងសម្ភារឧបទេសសម្រាប់ការបង្រៀន/ការរៀន ក៏ត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួនតាមស្ដង់ដារថ្មីនេះដែរ។

## ២. គោលបំណង និងវត្ថុបំណងនៃការផ្ដល់សៀវភៅសិក្សាគោល

### ក. គោលបំណងនៃការផ្ដល់សៀវភៅសិក្សាគោល

ការផ្ដល់សៀវភៅសិក្សាគោល ជាការគាំទ្រចំពោះគោលដៅទូទៅរបស់ការអប់រំ ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំកម្រិតមូលដ្ឋាន និងមធ្យមសិក្សា តាមរយៈការផ្ដល់សៀវភៅសិក្សាគោលសម្រាប់សិស្ស និងសម្រាប់គ្រូ សៀវភៅអំណានបន្ថែមនិងសម្ភារឧបទេស។ល។ ដែលគាំទ្រដល់កម្មវិធីសិក្សា។





### ខ. វត្ថុបំណងនៃការផ្គត់ផ្គង់សៀវភៅសិក្សាគោល

វត្ថុបំណងនៃការផ្គត់ផ្គង់សៀវភៅសិក្សាគោលរួមមាន៖

១. **លទ្ធភាពទទួលបាន**: សិស្សានុសិស្សទាំងអស់នៅគ្រប់កម្រិតសិក្សាទាំងកម្រិតមូលដ្ឋាន និងកម្រិតមធ្យមសិក្សាមានលទ្ធភាពទទួលបានសៀវភៅសិក្សាគោលគ្រប់គ្រាន់ ឬមានលទ្ធភាពអាចទិញសៀវភៅសិក្សាផ្សេងទៀតដែលត្រូវបានអនុម័តឱ្យប្រើដោយក្រសួងអប់រំ។

២.**គុណភាព**: សៀវភៅសិក្សាគោលដែលត្រូវបានអនុម័តឱ្យប្រើត្រូវមានគុណភាពខ្ពស់ និងគាំទ្រដល់កម្មវិធីសិក្សាសម្រាប់មុខវិជ្ជានីមួយៗ និងគ្រប់កម្រិតថ្នាក់។

៣.**ការគាំទ្រ**: រាល់សៀវភៅសិក្សាគោលទាំងអស់ត្រូវមានការគាំទ្រពីសៀវភៅសិក្សាគោលសម្រាប់គ្រូ និងសម្ភារឧបទេសបន្ថែមសម្រាប់ការរៀន និងការបង្រៀនឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបានតាមលទ្ធភាពហិរញ្ញវត្ថុដែលមាន។

## ៣. នីតិវិធីដើម្បីសម្រេចបានវត្ថុបំណងទី ១: លទ្ធភាពដើម្បីទទួលបានសៀវភៅអប់រំ

### ក. ការផ្ដល់មូលនិធិសម្រាប់ការអភិវឌ្ឍសៀវភៅសិក្សាគោល

ការផ្ដល់មូលនិធិ គឺបានមកតាមរយៈកញ្ចប់ថវិកាពីក្រសួងអប់រំ ដែលអនុម័តដោយក្រសួងហិរញ្ញវត្ថុ ហេតុនេះការស្នើសុំថវិកាសម្រាប់សៀវភៅសិក្សាគោលទៅស្ថាប័នទាំងពីរនេះត្រូវតែមានអំណះអំណាងទិន្នន័យ ច្បាស់លាស់ ដើម្បីឱ្យមានការផ្ដល់មូលនិធិគ្រប់គ្រាន់សម្រាប់គាំទ្រចំពោះអាទិភាពនេះ។

ការផ្តល់សៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាទាំងអស់នៅគ្រប់កម្រិតថ្នាក់ជាអាទិភាពមួយដ៏ខ្ពស់បំផុត។ ចាំបាច់ត្រូវផ្តល់មូលនិធិគ្រប់គ្រាន់ដើម្បីអភិវឌ្ឍ បោះពុម្ព និងចែកចាយសៀវភៅសិក្សាគោលទាំងនេះដែលជាការគាំទ្រដល់អាទិភាពនេះ។ បច្ចុប្បន្នសៀវភៅសិក្សាគោលត្រូវបានអភិវឌ្ឍឡើងដោយផ្អែកលើមូលដ្ឋានមូលនិធិដែលមាន ដែលបានបង្កឱ្យមានការខ្វះខាតសៀវភៅសិក្សាគោលទាំងនេះ។

## ខ. ការគ្រប់គ្រងនិងផ្គត់ផ្គង់សៀវភៅសិក្សាគោល

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាមានតួនាទីពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សាថ្មី និងប្រព័ន្ធនៃការប្រឡងផងដែរ។ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាមានភារកិច្ចទទួលខុសត្រូវលើដំណើរការនៃការអភិវឌ្ឍសៀវភៅសិក្សាគោល។

ដោយហេតុថា សៀវភៅសិក្សាគោលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងកម្មវិធីសិក្សា ហេតុនេះការផ្គត់ផ្គង់សៀវភៅសិក្សាគោលត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។ បច្ចុប្បន្ននេះនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាមិនមែនជាអ្នកអនុម័តលើការដាក់ឱ្យប្រើប្រាស់សៀវភៅសិក្សាគោលទេ។ កាអនុម័តនេះ គឺជាការងាររបស់ក្រុមប្រឹក្សាអនុម័តសម្ភារសិក្សាដែលនៅដាច់ពីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។ ការដកភារកិច្ចពីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាដែលមានបេសកកម្មអនុម័តសម្ភារសិក្សាប្រគល់ឱ្យស្ថាប័នខាងក្រៅដូចជាក្រុមប្រឹក្សាអនុម័តសម្ភារសិក្សា នាំឱ្យមានការពន្យារពេលដែលមិនចាំបាច់ និងមិនមានមូលហេតុសមស្របបើគិតទៅលើប្រសិទ្ធភាព។៚





## គ. ការរៀបចំយន្តការសៀវភៅសិក្សាគោល

បច្ចុប្បន្នទោះបីជាមានការផ្សព្វផ្សាយដើម្បីដាក់ឱ្យមានការដេញថ្លៃការអភិវឌ្ឍ និងបោះពុម្ពសៀវភៅសិក្សាគោលក្តី ប៉ុន្តែជាលទ្ធផលមានអ្នកដេញថ្លៃតែមួយគត់ដែលមានសមត្ថភាព គឺគ្រឹះស្ថានពុម្ព និងចែកផ្សាយ។ បន្ទាប់មកគ្រឹះស្ថានពុម្ព និងចែកផ្សាយរកអ្នកនិពន្ធពីក្នុងចំណោមមន្ត្រីនៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។ ការបំប៉នសមត្ថភាពជំនាញដល់មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាក្នុងការរៀបចំសៀវភៅបន្ទុកដែលសមស្របសម្រាប់ដាក់បញ្ចូលនៅក្នុងឯកសារដេញថ្លៃ គឺជាចំណុចអាទិភាព ។

តួនាទីរបស់មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានៅក្នុងការងារផ្គត់ផ្គង់សៀវភៅសិក្សាគោល គឺត្រូវរៀបចំយន្តការសម្រាប់ក្រុមអ្នករៀបរៀង។ អ្នករៀបរៀងនឹងទទួលខុសត្រូវក្នុងការសរសេរការណែនាំអំពីតម្រូវការ ដែលទាមទារនៅក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោលដើម្បីបង្កើតជាលក្ខណៈវិនិច្ឆ័យដែលនឹងយកទៅវាយតម្លៃសមត្ថភាពរបស់គូប្រជែងដែលជាអ្នកបោះពុម្ពផ្សាយ ក្នុងគោលដៅដើម្បីទទួលយក ឬបដិសេធស្នាដៃ ដែលពួកគេបានអភិវឌ្ឍ ថាតើសៀវភៅទាំងនេះឆ្លើយតបនឹងតម្រូវការឬអត់ និងអាចអនុម័តឱ្យប្រើប្រាស់នៅតាមសាលារៀនឬទេ។

## ឃ. ការបោះពុម្ពសៀវភៅសិក្សាគោល

ដើម្បីលើកកម្ពស់វិស័យបោះពុម្ពផ្សាយឯកជន ដំណើរការដែលបានរៀបរាប់ខាងលើនឹងចាំបាច់ត្រូវតែមានតម្លាភាព និងផ្សព្វផ្សាយជាសាធារណៈយ៉ាងទូលំទូលាយ។ សហគ្រាសបោះពុម្ពផ្សាយដែលមានសក្តានុពលនឹងទទួលបានការណែនាំយ៉ាងច្បាស់លាស់អំពីអ្វីដែលត្រូវធ្វើ ព្រមទាំងលក្ខណៈវិនិច្ឆ័យប្រកបដោយតម្លាភាពសម្រាប់វិនិច្ឆ័យលើស្នាដៃ។៚

វត្ថុបំណងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺធ្វើយ៉ាងណាបង្កើតឱ្យមានសហគ្រាសបោះពុម្ពផ្សាយឯកជនច្រើននៅក្នុងប្រទេស។ ឆ្លើយតបវត្ថុបំណងនេះ គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយដែលកាលពីមុន គឺជាផ្នែកមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានប្រែក្លាយជាសហគ្រាសសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ប៉ុន្តែនៅតែជាកម្មសិទ្ធិរបស់រដ្ឋ និងស្ថិតក្រោមការគ្រប់គ្រងដឹកនាំរបស់រដ្ឋនៅឡើយ។ដំណើរការអភិវឌ្ឍសៀវភៅសិក្សាគោលដែលរៀបចំយ៉ាងច្បាស់លាស់តាមរយៈនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា បូករួមជាមួយដំណើរការដេញថ្លៃដែលមានតម្លាភាពនឹងជួយពន្លឿនការចូលរួមអភិវឌ្ឍសៀវភៅសិក្សាពីវិស័យបោះពុម្ពផ្សាយឯកជននានាជាក់ជាមិនខាន។

### ង. ការចែកចាយសៀវភៅសិក្សា

គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឬសហគ្រាសឯកជនដែលទទួលបានសេវាក្នុងការផ្គត់ផ្គង់សៀវភៅសិក្សានឹងដឹកជញ្ជូនសៀវភៅសិក្សាទៅដល់សាលារៀនទូទាំងប្រទេសប្រកបដោយប្រសិទ្ធភាព។គុណសម្បត្តិនៃការដាក់ដេញថ្លៃការផ្គត់ផ្គង់ និងបោះពុម្ពផ្សាយសៀវភៅសិក្សាគោលដល់វិស័យឯកជន គឺយើងអាចដាក់តម្រូវការក្នុងការចែកចាយសៀវភៅទៅដល់សាលារៀនបញ្ចូលទៅក្នុងដំណើរការដេញថ្លៃដោយការបង់ប្រាក់នឹងត្រូវធ្វើឡើងនៅពេលមានការចុះហត្ថលេខាទទួលទំនិញដែលបានដឹកជូនដោយជោគជ័យ។

### ច. ការគ្រប់គ្រងសៀវភៅសិក្សាគោល

បច្ចុប្បន្នអត្រានៃការបាត់បង់សៀវភៅសិក្សាមានកម្រិតខ្ពស់ ព្រោះសមត្ថភាពការគ្រប់គ្រង និងការថែរក្សាសៀវភៅរបស់មន្ត្រីគ្រប់គ្រងសៀវភៅសិក្សាគោលនៅមានកម្រិត រួមនិងសាលារៀនមួយចំនួនគ្មានបណ្ណាល័យ។





ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសៀវភៅសិក្សាគោលសាលារៀនចាំបាច់ត្រូវមានបណ្ណាល័យ ប្រកបដោយស្តង់ដារ ( មានបរិក្ខាររក្សាទុកសៀវភៅទូរដាក់ឯកសារ...)និងបំប៉នសមត្ថភាពមន្ត្រីគ្រប់គ្រងសៀវភៅសិក្សា នាយកសាលារៀនស្តីអំពីការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោល។

## ៤. នីតិវិធីដើម្បីសម្រេចបាននូវវត្ថុបំណងទី២: គុណភាពនៃ សៀវភៅអប់រំ

### ក. ផែនការដើម្បីផលិតសៀវភៅអប់រំ

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាបានធ្វើផែនការកម្មវិធីជាដំណាក់កាលៗ ដើម្បីអភិវឌ្ឍសៀវភៅសិក្សាគោលសម្រាប់សិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូ ក្នុងពេលមធ្យម។ ផែនការនេះ រងនូវភាពរឹតត្បិតដោយសារតែថវិកាមានកម្រិតកំណត់ ជាហេតុធ្វើឱ្យការអនុវត្តមានភាពយឺតយ៉ាវជាងអ្វីដែលយើងប្រាថ្នាចង់បានជាខ្លាំង។

ផែនការរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានាពេលបច្ចុប្បន្ន មានវិសាលភាពយ៉ាងទូលំទូលាយ និងផ្តល់នូវមូលដ្ឋានគ្រឹះដ៏ល្អ ដើម្បីអាចសម្រេចបានវត្ថុបំណងនៃអត្រា ១:១ គឺសៀវភៅមួយក្បាលគ្រប់មុខវិជ្ជាសម្រាប់សិស្សម្នាក់នៅគ្រប់ថ្នាក់ទាំងអស់។ ការងារនេះក្រសួងអប់រំ យុវជន និងកីឡាចាំបាច់ត្រូវពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាឱ្យបានថា មានមូលនិធិគ្រប់គ្រាន់ដើម្បីសម្រេចបាននូវផែនការអភិវឌ្ឍសៀវភៅសិក្សាគោល។

## ខ. ការសាងជំនាញសម្រាប់មន្ត្រីរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា បានចាប់ផ្តើមបណ្តុះបណ្តាលដល់មន្ត្រីរបស់ខ្លួន ដើម្បីត្រៀមខ្លួនបង្កើតសេចក្តីណែនាំនៅក្នុងការបញ្ចប់ធ្វើសៀវភៅសិក្សាគោល ប៉ុន្តែយើងនៅតែត្រូវការការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញបន្ថែមទៀតដើម្បីបង្កើនគុណភាពការអភិវឌ្ឍសៀវភៅសិក្សាគោល និងសម្ភារឧបទេសឱ្យមានគុណភាពខ្ពស់។

កម្មវិធីបណ្តុះបណ្តាលរយៈពេលវែង និងទូលំទូលាយ ដែលធ្វើឡើងដោយមន្ត្រីជាន់ខ្ពស់នៅក្នុងនាយកដ្ឋាននឹងត្រូវធ្វើឡើងដើម្បីធានាឱ្យបានថា អ្នកអភិវឌ្ឍសេចក្តីណែនាំក្នុងការបញ្ចប់ធ្វើសៀវភៅសិក្សា និងអ្នកអភិវឌ្ឍសៀវភៅសិក្សាគោល បន្តអភិវឌ្ឍ និងផ្តល់ជូននូវសម្ភារៈដែលមានគុណភាពខ្ពស់។ កម្មវិធីការបណ្តុះបណ្តាលនឹងត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ។

## គ. ការអនុម័តសៀវភៅសិក្សា

បច្ចុប្បន្នក្រុមប្រឹក្សាអនុម័តសម្ភារសិក្សាមិនស្ថិតក្នុងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាទេ។ ចំណុចនេះ ធ្វើឱ្យការងារមិនមានប្រសិទ្ធភាពទេ ប្រសិនបើយើងគិតអំពីបញ្ហាពេលវេលា និងការដកហូតដំណើរការនៃការអនុម័តចេញពីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ព្រោះមន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាជាអ្នកមានសមត្ថភាពខ្ពស់បំផុតក្នុងការវិនិច្ឆ័យលើគុណភាពសៀវភៅសិក្សាគោល និងសម្ភារសិក្សាឱ្យស្របទៅតាមកម្មវិធីសិក្សា។ ក្រុមប្រឹក្សាអនុម័តសម្ភារសិក្សាត្រូវដាក់នៅក្នុងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។





មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា មានភារកិច្ចសំខាន់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍកម្មវិធីសិក្សា សៀវភៅសិក្សា ចូលរួមដំណើរការនៃការប្រឡង និងការអនុម័តលើសៀវភៅសិក្សា ព្រោះថាមន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាមានចំណេះដឹងយ៉ាងជិតស្និទ្ធបំផុតនឹងខ្លឹមសារ និងទិសដៅរបស់កម្មវិធីសិក្សា។

## ឃ. ការធានាឱ្យបាននូវសមភាព និងការរួមបញ្ចូលនៅក្នុងសៀវភៅសិក្សា

សៀវភៅសិក្សា និងសម្ភារឧបទេសទាំងអស់ដែលប្រើប្រាស់ក្នុងសាលារៀនត្រូវតែបញ្ជ្រាបផ្នែកយេនឌ័រ និងធ្វើយ៉ាងណាកុំឱ្យមានការបង្ហាញចេញមកនូវគំនិតរើសអើង។ កម្មវិធីសិក្សា សៀវភៅសិក្សា និងការប្រឡង ត្រូវវាយតម្លៃជាប្រចាំ ដើម្បីធានាឱ្យបាននូវតួនាទីផ្នែកយេនឌ័រ។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានឹងពិនិត្យឡើងវិញទៅលើសៀវភៅសិក្សា និងសម្ភារឧបទេសដើម្បីរកឱ្យឃើញការចូលរួមផ្នែកយេនឌ័រនៅក្នុងកម្មវិធីសិក្សា។

## ង. ការរក្សាគុណភាពនៅក្នុងការអប់រំ

កម្មវិធីសិក្សា សៀវភៅសិក្សា និងការប្រឡងនឹងត្រូវបានវាយតម្លៃជាប្រចាំ ដើម្បីធានាឱ្យបាននូវភាពសមស្របជាមួយស្ថានភាពអភិវឌ្ឍរបស់ប្រទេស។ ការពិនិត្យឡើងវិញជាប្រចាំទៅលើកម្មវិធីសិក្សានឹងអាចកំណត់នូវតម្រូវការថ្មីៗដែលត្រូវកែសម្រួលកម្មវិធីសិក្សា និងសៀវភៅសិក្សាផងដែរ ដើម្បីឱ្យសៀវភៅសិក្សាអាចឆ្លុះបញ្ចាំងកម្មវិធីសិក្សា។

នាយកដ្ឋានកម្មវិធីសិក្សានឹងមានកាលវិភាគនៅក្នុងផែនការរយៈពេលមធ្យមរបស់ខ្លួន ដើម្បីពិនិត្យទៅលើកម្មវិធីសិក្សា និងសៀវភៅសិក្សាឡើងវិញ។

## ៥. នីតិវិធីដើម្បីសម្រេចបាននូវវត្ថុបំណងទី៣: ការគាំទ្រសម្រាប់សៀវភៅសិក្សា

### ក. ការគាំទ្រគ្រូបង្រៀន

គ្រូបង្រៀនភាគច្រើនមិនមានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការផ្លាស់ប្តូរការអនុវត្តនៅក្នុងថ្នាក់រៀន ពីការសង្កត់ធ្ងន់លើការបង្រៀន និងរៀនដោយវិធីសាស្ត្រទន្ទេញចាំមាត់ (គ្រូមជ្ឈមណ្ឌល)ជំនួសដោយការបង្រៀន និងរៀនដោយវិធីសាស្ត្របែបសកម្ម (សិស្សមជ្ឈមណ្ឌល)។ដូចនេះ តម្រូវឱ្យមានការគាំទ្រ និងបំប៉នសមត្ថភាពដល់គ្រូបង្រៀនដើម្បីឱ្យពួកគាត់អាចមានសមត្ថភាពអនុវត្តវិធីសាស្ត្របែបសកម្ម (សិស្សមជ្ឈមណ្ឌល) នៅក្នុងថ្នាក់រៀន។ សៀវភៅសិក្សាសម្រាប់គ្រូគឺជាមគ្គុទ្ទេសក៍ណែនាំអំពីវិធីសាស្ត្របង្រៀន និងរៀនបែបថ្មី (បែបសកម្ម)មានសារៈសំខាន់ណាស់ក្នុងការគាំទ្រដល់គ្រូបង្រៀនដូចដែលបានលើកឡើង។ ការគាំទ្របន្ថែមត្រូវផ្តល់ឱ្យតាមរយៈយន្តការការបណ្តុះបណ្តាលក្នុងអំឡុងពេលកំពុងបម្រើការងារ (វិក្រឹតការ)។

កម្មវិធីវិក្រឹតការនឹងជួយដល់គ្រូបង្រៀនក្នុងបង្កើតសម្ភារឧបទេសបានដោយខ្លួនឯង ដូចជាសៀវភៅកិច្ចតែងការបង្រៀនជាដើម។

ការផ្លាស់ប្តូរអាកប្បកិរិយារបស់គ្រូបង្រៀន គឺជាការងារមួយដ៏លំបាក ហេតុនេះហើយត្រូវការនូវការគាំទ្រដ៏ធំធេងដើម្បីធានាឱ្យបានថា គ្រូបង្រៀនមានសម្ភារឧបទេសល្អៗនិងគ្រប់គ្រាន់ដែលនឹងជួយពួកគាត់ក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនបែបសកម្ម។





### ខ. សម្ភារឧបទេសបន្ថែម

សម្ភារឧបទេសបន្ថែម រួមមានសៀវភៅអំណាន សៀវភៅជំនួយស្មាតីផ្នែកគណិតវិទ្យា វិទ្យាសាស្ត្រងាយៗ និងសម្ភារៈប្រើប្រាស់ផ្សេងទៀត ដូចជាក្រដាស ខ្មៅដៃ ស្កុតបិទ។ល។ គួរផ្តល់ជូនគ្រូបង្រៀនក្នុងក្របខណ្ឌថវិកាដែលមានដើម្បីជួយសម្រួលដល់គ្រូបង្រៀនឱ្យអាចបង្កើតឧបករណ៍ជំនួយក្នុងការបង្រៀនដោយខ្លួនឯង និងដើម្បីលើកកម្ពស់ការសិក្សាបែបសកម្ម ជាពិសេសសម្រាប់កុមារថ្នាក់ដំបូង។

ការផ្តល់សៀវភៅសិក្សាគោលសម្រាប់សិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូ គឺជាអាទិភាពបំផុតសម្រាប់ការបង្រៀន និងរៀនប៉ុន្តែសម្ភារឧបទេសជាពិសេសគឺបន្ថែមអំណាន សម្រាប់កុមារថ្នាក់ដំបូង គឺមានសារៈសំខាន់ណាស់ក្នុងការជួយជម្រុញឱ្យកុមារមានទម្លាប់ក្នុងការអាន។

### គ. ការផ្តល់បណ្ណាល័យ

គោលដៅរយៈពេលវែងសម្រាប់សាលាទាំងអស់នៅក្នុងប្រទេសកម្ពុជា គឺការបង្កើតបណ្ណាល័យមួយ ប្រកបដោយស្តង់ដារដែលបំពាក់ទៅដោយសៀវភៅសិក្សា និងឯកសារគ្រប់គ្រាន់ដើម្បីជម្រុញឱ្យមានទម្លាប់នៃការអាន និងការសិក្សាស្រាវជ្រាវដែលជាជំនាញដ៏ចាំបាច់មួយសម្រាប់ការរៀនអស់មួយជីវិត។

ការបណ្តុះបណ្តាលគ្រូបង្រៀនមុនពេលចូលបម្រើការងារ និងក្នុងពេលកំពុងបម្រើការងារនឹងជួយឱ្យគ្រូបង្រៀនមានសមត្ថភាពក្នុងការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោលបានល្អនៅក្នុងសាលារៀន។ ការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោលបានល្អមានសារៈសំខាន់ណាស់ដើម្បីរួម

ចំណែកកាត់បន្ថយការបាត់បង់សៀវភៅសិក្សា និងជួយសម្រេចបានគោលដៅក្នុងការផ្តល់សៀវភៅសិក្សាគោល តាមអត្រាសៀវភៅមួយក្បាលសម្រាប់សិស្សមួយម្នាក់គ្រប់មុខវិជ្ជាដល់សិស្សគ្រប់ៗរូប។ ការកាត់បន្ថយការបាត់បង់សៀវភៅសិក្សាគោល មានន័យថា យើងអាចផ្ទេរធនធានសម្រាប់យកទៅអភិវឌ្ឍបណ្ណាល័យ។ ■



# មគ្គុទ្ទេសក៍ សម្រាប់ការអភិវឌ្ឍ សៀវភៅសិក្សាគោល

# មាតិកា

ទំព័រ

១. សេចក្ដីផ្ដើម ........................................ ១៩

២. ដំណើរការដេញថ្លៃសៀវភៅសិក្សាគោល
ប្រកបដោយតម្លាភាព និងគណនេយ្យភាព .................... ២០

៣. សៀវភៅសិក្សាគោល និងកម្មវិធីសិក្សាថ្មី .................... ២៦

៤. ការរៀបចំមគ្គុទ្ទេសក៍ក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល..... ២៩

៥. ការរៀបចំជំពូកគំរូ ........................................ ៣០

៦ ការអនុម័តសៀវភៅសិក្សាគោល .................................. ៣៣

៧ ការអភិវឌ្ឍ និងការអនុម័តសៀវភៅសិក្សាគោលសម្រាប់គ្រូ.. ៣៣

ឯកសារភ្ជាប់

១. លក្ខណៈលម្អិតរបស់សៀវភៅសិក្សាគោល
២. ទម្រង់វាយតម្លៃសៀវភៅសិក្សាគោល



មគ្គុទ្ទេសក៍សម្រាប់ការអភិវឌ្ឍសៀវភៅសិក្សាគោល

# ១. សេចក្ដីផ្ដើម

គោលការណ៍ណែនាំទាំងនេះត្រូវបានបង្កើតឡើងដោយមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្រោមកិច្ចជួយជ្រោមជ្រែងពីសំណាក់អ្នកពិគ្រោះការអន្តរជាតិនៃគម្រោងលើកកម្ពស់គុណភាពអប់រំ (EEQP) ដើម្បីបង្កើតការណែនាំក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោលប្រកបដោយគុណភាពខ្ពស់ និងដើម្បីគាំទ្រដល់កម្មវិធីសិក្សាថ្មីដែល អនុវត្តនៅគ្រប់សាលារៀនទូទាំប្រទេសកម្ពុជានៅឆ្នាំ២០០៩។ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាត្រូវអនុវត្តគោលការណ៍ណែនាំនេះដើម្បីណែនាំដល់គ្រឹះស្ថានសាធារណៈ និងសហគ្រាសឯកជនក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល។

គោលការណ៍ណែនាំនេះស្របទៅនឹងគោលបំណង និងវត្ថុបំណងរបស់កម្មវិធីសិក្សាថ្មី ដែលផ្ដោតលើការយកចិត្តទុកដាក់លើការចូលរួមឱ្យកាន់តែច្រើន និងសកម្មពីសំណាក់អ្នកសិក្សា និងអាចធ្វើស្វ័យសិក្សាបានដោយខ្លួនឯង។ សៀវភៅសិក្សាគោលត្រូវគាំទ្រចំពោះទិសដៅទាំងនេះនៅក្នុងកម្មវិធីសិក្សា។

សៀវភៅសិក្សាគោលមានសារៈសំខាន់ជាពិសេសដែលអនុញ្ញាតឱ្យអ្នកសិក្សាមានភាពឯករាជ្យទៅលើស្ថាន ភាពជាក់លាក់មួយនៅក្នុងថ្នាក់រៀន។ គ្រូបង្រៀនមួយចំនួនមិនមានសមត្ថភាព ( គុណវុឌ្ឍពេញលេញ) ក្នុងការបង្រៀនមុខវិជ្ជាឯកទេសទេ។ ដូចនេះសៀវភៅសិក្សាគោលដែលប្រកបដោយគុណភាពល្អ នឹងជួយដល់ការបង្រៀន និងរៀន ប្រកបដោយប្រសិទ្ធភាព។ គោលការណ៍ណែនាំនេះជួយដល់អ្នកនិពន្ធក្នុងការរៀបចំលក្ខណៈលម្អិតរបស់សៀវភៅសិក្សាគោល និងជំពូកគំរូ។

ក្រុមប្រឹក្សាអនុម័តដើរតួយ៉ាងសំខាន់នៅក្នុងការវាយតម្លៃសៀវភៅសិក្សាគោល។ គោលការណ៍ទាំងនេះជម្រុញឱ្យមានកិច្ចសហការ និងធ្វើការ

ជាក្រុមក្នុងការរៀបចំលក្ខណៈលម្អិតរបស់សៀវភៅសិក្សាគោល និងជំពូកគំរូ ដើម្បីធ្វើយ៉ាងណាឱ្យឯកសារនេះមានគុណភាពខ្ពស់តាមដែលអាចធ្វើទៅបាន។ អ្នករៀបចំលក្ខណៈលម្អិតរបស់សៀវភៅសិក្សាគោល និងជំពូកគំរូគួរតែចូលរួមយ៉ាងជិតស្និតក្នុងការវាយតម្លៃដំណើរការដេញថ្លៃសៀវភៅ និងផ្តល់ជាអនុសាសន៍ថាតើសំណើការចូលរួមដេញថ្លៃសៀវភៅបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យដែលបានតម្រូវឱ្យមានហើយ ឬនៅ។

សៀវភៅសិក្សាគោលសម្រាប់គ្រូក៏គួរត្រូវបានអភិវឌ្ឍ និងវាយតម្លៃក្នុងស្តង់ដារមួយខ្ពស់ដូចជាសៀវភៅសិក្សាគោលសម្រាប់សិស្សដែរ។ នីតិវិធីក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល និងលក្ខណៈវិនិច្ឆ័យដើម្បីវិនិច្ឆ័យទៅលើគុណភាពរបស់សៀវភៅសិក្សាគោលសម្រាប់សិស្ស ក៏អាចយកមកអនុវត្តនៅក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោលសម្រាប់គ្រូផងដែរ។ សៀវភៅសិក្សាគោលសម្រាប់គ្រូដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់អាកប្បកិរិយារបស់គ្រូបង្រៀន និងជួយជម្រុញការអនុវត្តយុទ្ធសាស្ត្រនានាដែលសមស្របចំពោះទិសដៅរបស់កម្មវិធីសិក្សាថ្មី។

## ២. ដំណើរការដេញថ្លៃសៀវភៅសិក្សាគោលប្រកបដោយតម្លាភាព និងគណនេយ្យភាព

### ២.១ គោលការណ៍ដេញថ្លៃសៀវភៅសិក្សាគោលសម្រាប់វិស័យឯកជន

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់រួចហើយថា ការអភិវឌ្ឍ និងបោះពុម្ពផ្សាយសៀវភៅសិក្សាគោលសម្រាប់ប្រើប្រាស់តាមសាលារៀនក្នុងប្រទេសកម្ពុជានឹងត្រូវធ្វើឡើងតាមរយៈដំណើរការដេញថ្លៃដោយមានការចូលរួមពី





សហគ្រាសអ្នកបោះពុម្ពផ្សាយឯកជន។ ខាងក្រោមនេះជាគោលការណ៍មូលដ្ឋាននៃដំណើរការដេញថ្លៃ ៖

ក) ការដេញថ្លៃអភិវឌ្ឍសៀវភៅសិក្សាគោលត្រូវធ្វើឡើងស្របទៅតាមគោលការណ៍សុច្ចរិតភាព តម្លាភាព និងគណនេយ្យភាព។

ខ) ដំណើរការនេះត្រូវអនុវត្ត និងទទួលខុសត្រូវដោយនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាដែលជាសេនាធិការឱ្យក្រសួងអប់រំ យុវជន និងកីឡា។

គ) គណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សាគោលសម្រាប់មុខវិជ្ជានីមួយៗនឹងត្រូវបានបង្កើតឡើង ដោយប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។ គណៈកម្មាធិការនេះមានតួនាទីពិនិត្យមើលឯកសារ និងដំណើរការនៃការដេញថ្លៃ។

ឃ) គណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សាគោលនឹងរៀបចំលក្ខណៈលម្អិតរបស់សៀវភៅសិក្សាគោល និងជំពូកគំរូសម្រាប់គ្រប់មុខវិជ្ជានីមួយៗព្រមទាំងសៀវភៅសិក្សាគោលសម្រាប់គ្រូ។

ង) លក្ខណៈលម្អិតរបស់សៀវភៅសិក្សា និងជំពូកគំរូត្រូវគោរពយ៉ាងខ្ជាប់ខ្ជួនតាមកម្មវិធីសិក្សាដែលត្រូវបានអនុម័តឱ្យប្រើប្រាស់សម្រាប់មុខវិជ្ជា និងកម្រិតថ្នាក់នីមួយៗ។

ច) គណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សាគោលទទួលខុសត្រូវក្នុងការវាយតម្លៃស្នាដៃ និងធ្វើចំណាត់ថ្នាក់ស្នាដៃរបស់សហគ្រាសបោះពុម្ពផ្សាយ។

ង) គណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សាគោលទទួលខុសត្រូវក្នុងការណែនាំអ្នកទទួលបានសិទ្ធិ (អ្នកឈ្នះ)ក្នុងការអភិវឌ្ឍសៀវភៅសិក្សាទៅដល់ក្រុមប្រឹក្សាអនុម័តសម្ភារៈសិក្សា។

ជ) គណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សាគោលទទួលខុសត្រូវក្នុងការតាមដានការអនុវត្តកិច្ចសន្យាក្នុងការអភិវឌ្ឍសៀវភៅសិក្សា និងបោះពុម្ពផ្សាយ។

## ២.២ ដំណើរការដេញថ្លៃការអភិវឌ្ឍសៀវភៅសិក្សាគោល

### ២.២.១ ការរៀបចំឯកសារដេញថ្លៃ

ក) នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាត្រូវកសាងផែនការច្បាស់លាស់សម្រាប់ការអភិវឌ្ឍសៀវភៅសិក្សាគោលសម្រាប់សិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូ។

ខ) នាយកនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាកំណត់សមាជិកភាព និងតែងតាំងគណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សាគោលសម្រាប់មុខវិជ្ជា និងកម្រិតថ្នាក់នីមួយៗនៅក្នុងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាដោយធានាឱ្យបាននូវសុច្ចរិតភាព។

គ) គណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សាគោលត្រូវកំណត់ប្រភេទនៃសៀវភៅសិក្សាគោល និង/ឬសៀវភៅសិក្សាគោលសម្រាប់គ្រូដែលត្រូវអភិវឌ្ឍ។

ឃ) គណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សាគោលណែនាំកម្មវិធីសិក្សា កំណត់ម៉ោងសិក្សា និងបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃដល់អ្នកដេញថ្លៃ។





ង) គណៈកម្មាធិការអភិវឌ្ឍនិងអនុម័តសៀវភៅសិក្សាគោលបញ្ជាក់អំពីចំនួនច្បាប់ដែលត្រូវបោះពុម្ពនិងទីតាំងសាលារៀន ឬឃ្លាំងសៀវភៅដែលនឹងត្រូវដឹកសៀវភៅចែកជូន។

ច) គណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សាគោលត្រូវរៀបចំលក្ខណៈលម្អិតរបស់ជំពូកគំរូ សៀវភៅសិក្សាគោលសម្រាប់សិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូ។

ឆ) គណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សាគោលរៀបចំឯកសារស្តីពីវិសាលភាពសេវាកម្ម (SOS) និងព្រាងកិច្ចសន្យា។

ជ) បញ្ជាក់អំពីទម្រង់លិខិតសុំចូលរួមដេញថ្លៃ ឧទាហរណ៍ទម្រង់ឯកសារបែបអេឡិចត្រូនិចអាចអនុញ្ញាតឱ្យចូលរួមដេញថ្លៃបានដែរ ឬទេ?

ឈ) បញ្ជាក់អំពីរបៀប និងទីកន្លែងដែលត្រូវដាក់ពាក្យចូលរួមដេញថ្លៃ និងកាលបរិច្ឆេទផុតកំណត់នៃការដាក់ពាក្យ។

ញ) ព័ត៌មានលម្អិតផ្នែកហិរញ្ញវត្ថុនៃការដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត និងត្រូវដាក់ភ្ជាប់ជាមួយពាក្យស្នើសុំចូលរួមដេញថ្លៃ។

ដ) នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាចាត់មន្ត្រីសម្រាប់ទំនាក់ទំនងដើម្បីឆ្លើយតបទៅនឹងសំណួរនានាទាក់ទងនឹងឯកសារដេញថ្លៃ។

ឋ) រៀបចំឯកសារសំណើដេញថ្លៃ។

### ២.២.២ ការអំពាវនាវរកអ្នកដេញថ្លៃ (ការផ្សាយពាណិជ្ជកម្ម)

ឌ) ចុះផ្សាយអត្ថបទអំពាវនាវរកអ្នកចូលរួមអភិវឌ្ឍសៀវភៅសិក្សាតាមរយៈសារព័ត៌មាន ឬគេហទំព័រ។

ឆ) ចែកឯកសារដេញថ្លៃឱ្យសហគ្រាសសាធារណៈក្រុមហ៊ុនឯកជន ដែលចូលរួមអភិវឌ្ឍសៀវភៅសិក្សា។

ណ) រៀបចំកម្មវិធីផ្តល់ព័ត៌មានជាសាធារណៈសម្រាប់ឆ្លើយតបទៅនឹងសំណួរទាក់ទងអំពីឯកសារដេញថ្លៃរបស់សហគ្រាសសាធារណៈ ឬក្រុមហ៊ុនឯកជន។

## ២.២.៣ ការទទួលសំណើរអ្នកដេញថ្លៃ

ត) រៀបចំការិយាល័យទទួលឯកសារ ឬប្រអប់សំបុត្រចាក់សោជិតនៅកន្លែងដែលសាធារណៈជនអាចដាក់ឯកសារបាន។

ថ) រៀបចំកត់ត្រាចំនួនអ្នកចូលរួមអ្នកដេញថ្លៃឱ្យបានត្រឹមត្រូវ។

ទ) អ្នកចូលរួមអ្នកដេញថ្លៃត្រូវនៅក្នុងបន្ទប់បិទទ្វារដាច់ដោយឡែក ដោយមិនបើកទ្វាររហូតទាល់តែគណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សាគោលបានមកដល់។

## ២.២.៤ ការវាយតម្លៃលើឯកសារដេញថ្លៃ

ធ) ឯកសារដេញថ្លៃទាំងអស់នឹងត្រូវបើកនៅក្នុងកិច្ចប្រជុំជាសាធារណៈរបស់គណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សា។

ន) ពិនិត្យមើលថាតើឯកសារដេញថ្លៃឆ្លើយតបទៅនឹងលក្ខណៈលម្អិតជាក់លាក់ដែរ ឬទេ។

ប) សមាជិកគណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សាធ្វើការវាយតម្លៃដោយឯករាជ្យទៅលើសំណើរបច្ចេកទេសដែលទទួលបានធៀបទៅនឹងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ។





ផ) សមាជិកគណៈកម្មាធិការអភិវឌ្ឍ និងវាយតម្លៃសៀវភៅសិក្សាគោលរៀបលំដាប់ថ្នាក់ឯកសារដេញថ្លៃ យោងទៅតាមពិន្ទុធៀបទៅនឹងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ។

ព) បើកឯកសារផ្នែកហិរញ្ញវត្ថុដែលចូលរួមអ្នកដេញថ្លៃនៅចំពោះមុខគណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សាគោល និងដាក់ពិន្ទុលម្អិតផ្នែកហិរញ្ញវត្ថុធៀបទៅនឹងសំណើផ្នែកបច្ចេកទេស។

ភ) គណៈកម្មាធិការអភិវឌ្ឍនិងអនុម័តសៀវភៅសិក្សាគោលត្រូវជ្រើសយកសំណើដែលជាប់លេខមួយ។

ម) អ្នកចូលរួមដេញថ្លៃទាំងអស់នឹងទទួលការជូនដំណឹងថា តើឯកសារដេញថ្លៃរបស់ពួកគាត់បានជោគជ័យ ឬមិនបានជោគជ័យ។

## ២.២.៥ ការចរចាកិច្ចសន្យាជាមួយអ្នកដេញថ្លៃជាប់លំដាប់ថ្នាក់ទី១

## ២.២.៦ ការផ្តល់កិច្ចសន្យាជូនចំពោះអ្នកដេញថ្លៃជាប់លំដាប់ថ្នាក់ទី១ ប្រសិនបើការចរចាទទួលបានជោគជ័យ

## ២.២.៧ ការតាមដានលើការអនុវត្តកិច្ចសន្យាដោយគណៈកម្មាធិការអភិវឌ្ឍនិងអនុម័តសៀវភៅសិក្សាគោល ដើម្បីធានាឱ្យបានការអនុវត្តកិច្ចសន្យាឆ្លើយតបទៅនឹងពេលវេលាសម្រេចបានតាមដំណាក់កាលសំខាន់ៗនៃកិច្ចសន្យា ការផាកពិន័យនឹងកើតមានចំពោះអ្នកមិនអនុវត្តតាមកិច្ចសន្យា។

# ៣. សៀវភៅសិក្សាគោល និងកម្មវិធីសិក្សាថ្មី

## ៣.១ កម្មវិធីសិក្សាគឺជាគន្លឹះសំខាន់សម្រាប់គ្រប់សកម្មភាពអប់រំ

កម្មវិធីសិក្សាថ្មីផ្តោតការយកចិត្តទុកដាក់លើការរៀន និងបង្រៀនដែលតម្រូវឱ្យសិស្សធ្វើសកម្មភាពក្នុងថ្នាក់រៀនច្រើនជាងសកម្មភាពគ្រូ។ កម្មវិធីសិក្សានេះលើកម្ពស់ការរៀនបែបសកម្មដែលពាក់ព័ន្ធជាមួយជីវិតប្រចាំថ្ងៃរបស់សិស្ស។ សៀវភៅសិក្សាគោល និងកត្តាផ្សេងៗទៀតដូចជាការបណ្តុះបណ្តាលគ្រូ និងការប្រឡងជាដើមត្រូវតែគាំទ្រកម្មវិធីសិក្សា។ កម្មវិធីសិក្សាគឺជាឯកសារចង្អុលទិសដៅសម្រាប់អភិវឌ្ឍសៀវភៅសិក្សាគោលនិងសកម្មភាពនានាដែលបញ្ជ្រាបក្នុងសៀវភៅសិក្សាគោល។

## ៣.២ ការរៀនបែបសកម្ម

កម្មវិធីសិក្សាថ្មីតម្រូវឱ្យការរៀន និងបង្រៀនផ្តោត និងយកចិត្តទុកដាក់ច្រើនជាងមុនលើសកម្មភាពសិក្សា ដែលដឹកនាំការរៀនសូត្រដោយអ្នកសិក្សាផ្ទាល់។ សៀវភៅសិក្សាគោលត្រូវគាំទ្រចំពោះលក្ខខណ្ឌផ្លាស់ប្តូរនៅក្នុងការសិក្សាទាំងនេះ ដើម្បីអាចសម្រេចបាននូវលទ្ធផលរំពឹងទុក។

គោលការណ៍លើកកម្ពស់ការរៀនបែបសកម្ម រួមមានៈ

ក) កុមារម្នាក់ គឺជាបុគ្គលម្នាក់ ដែលមើលឃើញពិភពលោកក្នុងលក្ខណៈពិសេសដោយឡែក។

ខ) កុមារមិនមែនជា "ផ្ទាំងសំពត់ស" នោះឡើយ ពោលគឺកុមារមានមូលដ្ឋានចំណេះដឹងពីកំណើតរួចមកហើយ។

គ) កុមារអាចរៀន និងទទួលចំណេះដឹងបានពីប្រភពផ្សេងៗជាច្រើនពោល គឺកុមារមិនមែនរៀនតែនៅក្នុងថ្នាក់រៀនប៉ុណ្ណោះទេ។





ឃ) កុមារចូលចិត្តចង់ចេះ ចង់ដឹងពីធម្មជាតិ ហើយពួកគេចង់ស្វែងយល់អំពីពិភពជុំវិញខ្លួន។

ង) តាមរយៈការពិភាក្សាជាមួយមិត្តភក្តិ និងអ្នកផ្សេងទៀត កុមារបានយល់ដឹងថាមានវិធីផ្សេងៗជាច្រើននៅក្នុងការវិភាគព័ត៌មាន។

ច) ការរៀន និងការស្រាវជ្រាវមានការលំបាកជាងការរំលឹកឡើងវិញ ឬការចងចាំព័ត៌មាន។

ឆ) កុមារបង្ហាញថា ពួកគេយល់អ្វីម៉្យាងនៅពេលដែលពួកគេអាចប្រើប្រាស់ចំណេះដឹងរបស់ខ្លួន ដើម្បីបង្កើតឱ្យមានព័ត៌មានថ្មីៗបន្ថែមទៀត។

## ៣.៣ សៀវភៅសិក្សាគោលគួរតែលើកកម្ពស់ជំនាញក្នុងការគិត "កម្រិតខ្ពស់"

កម្មវិធីសិក្សាថ្មីតម្រូវឱ្យអ្នកសិក្សាធ្វើការសិក្សា និងស្រាវជ្រាវច្រើនលើសពីការគ្រាន់តែរំលឹកឡើងវិញនូវព័ត៌មានដែលអាចនឹងក្លាយជាព័ត៌មានហួសសម័យ។ សៀវភៅសិក្សាគោលត្រូវរចនា និងអភិវឌ្ឍឡើងក្នុងលក្ខណៈមួយដែលគាំទ្រចំពោះជំនាញក្នុងការគិត "កម្រិតខ្ពស់" ដូចជាការយល់ ការវិភាគ ការយកចំណេះដឹងទៅអនុវត្ត ការសំយោគ និងការវាយតម្លៃ។

## ៣.៤ ការប្រើប្រាស់សៀវភៅសិក្សាគោលដើម្បីគាំទ្រដល់ការសិក្សា

សៀវភៅសិក្សាគោលត្រូវអភិវឌ្ឍឡើងក្នុងគោលបំណងជួយសម្រួលដល់អ្នកសិក្សានៅក្នុងៈ

ក) ការអភិវឌ្ឍបំណិនសិក្សាដែលឯករាជ្យ

ខ) ការពង្រឹងជំនាញក្នុងការសិក្សារបស់បុគ្គល

គ) ការអភិវឌ្ឍវិយាបទអន្តរបុគ្គល រួមទាំងជំនាញផ្នែកសង្គមផ្សេងៗ ផងដែរ។

គេអាចប្រើប្រាស់សៀវភៅសិក្សាគោលតាមវិធីផ្សេងៗជាច្រើនដើម្បីគាំទ្រដល់បទពិសោធន៍នៃការរៀន និងបង្រៀនដូចជាបទពិសោធន៍នៃការសិក្សាដោយខ្លួនឯងជាបុគ្គលទៅដល់ការសិក្សាដោយធ្វើការរួមគ្នាជាក្រុមក្រោមការដឹកនាំរបស់គ្រូ។

### ៣.៥ សកម្មភាពអនុវត្តជាក់ស្តែង

ក) ការងារចុះផ្ទាល់នៅមូលដ្ឋាន (សកម្មភាពក្រៅសាលា)

ខ)ការងារពិសោធន៍ (ភាសា កុំព្យូទ័រ វិទ្យាសាស្ត្រ។ល) ។

### ៣.៦ សកម្មភាពបុគ្គល

ក) ការរៀនដែលដឹកនាំដោយខ្លួនឯង

ខ)ការអនុវត្តកិច្ចការផ្ទះ

គ) ការរៀនជាលក្ខណៈបុគ្គល

ឃ) រៀនបែបឆ្លុះបញ្ចាំង ។

### ៣.៧ សកម្មភាពក្នុងក្រុមតូចៗ

ក) ការរៀនដោយមានការណែនាំពីគ្រូ និងពិភាក្សាតាមក្រុម

ខ) ការបង្ហាញឧទាហរណ៍ជាក់ស្តែង





គ) ការរៀនបែបសហការ

ឃ) ការជម្រុញទឹកចិត្ត។

### ៣.៨ សកម្មភាពក្នុងក្រុមធំៗ

ក) បទឧទ្ទេស

ខ) សិក្ខាសាលា ។

## ៤. ការរៀបចំការណែនាំនៅក្នុងការបញ្ជាធ្វើសៀវភៅសិក្សាគោល

នៅពេលដែលអនុវត្តដំណើរការដេញថ្លៃដើម្បីជ្រើសរើសក្រុមនិពន្ធ និងបោះពុម្ពសៀវភៅសិក្សាគោល កត្តាសំខាន់អ្នកដេញថ្លៃដែលមានសក្តានុពលចាំបាច់ដឹងព័ត៌មានឱ្យច្រើនបំផុតតាមដែលអាចធ្វើទៅបានអំពីអ្វីដែលជាតម្រូវការចង់បានរបស់គណៈកម្មាធិការអភិវឌ្ឍ និងអនុម័តសៀវភៅសិក្សាគោល។ ហេតុនេះការណែនាំនៅក្នុងការបញ្ជាធ្វើសៀវភៅសិក្សា និងជំពូកគំរូត្រូវផ្តល់នូវសូចនាករយ៉ាងច្បាស់លាស់អំពីស្តង់ដារដែលយើងចង់បាន។

ដំណើរការរៀបចំ (សន្ទឹក) លក្ខណៈលម្អិតរបស់សៀវភៅសិក្សាគោលគួរតែពិគ្រោះយោបល់ជាមួយក្រុមអ្នកជំនាញផ្នែកកម្មវិធីសិក្សាដើម្បីធានាថាខ្លឹមសារសៀវភៅសិក្សា វិធីសាស្ត្ររៀន និងបង្រៀន គឺស្របតាមកម្មវិធីសិក្សា។ ការងារនេះគឺមិនត្រូវអនុម័តដោយបុគ្គលតែម្នាក់នោះទេ។

យើងអាចបំពេញលក្ខណៈលម្អិតរបស់សៀវភៅសិក្សាគោលនៅក្នុងឯកសារភ្ជាប់ទីមួយដើម្បីជាការកត់ត្រាស្ដីអំពីដំណើរការនៃការអភិវឌ្ឍ។ សន្ទឹកនេះនឹងក្លាយទៅជាមគ្គុទ្ទេសក៍ ដើម្បីផ្ដល់ព័ត៌មានចាំបាច់ទាំងឡាយដែលនឹងអនុញ្ញាតឱ្យអ្នកដេញថ្លៃអាចអភិវឌ្ឍ និងបោះពុម្ពសៀវភៅសិក្សា។

## ៥. ការរៀបចំជំពូកគំរូ

ដំណាក់កាលខាងក្រោមនេះផ្ដល់នូវក្របខ័ណ្ឌការងារមួយសម្រាប់អ្នកអភិវឌ្ឍកម្មវិធីសិក្សារៀបចំជំពូកគំរូ ដែលនឹងត្រូវដាក់បញ្ចូលនៅក្នុងសន្ទឹកលក្ខណៈលម្អិតរបស់សៀវភៅសិក្សាគោលនៅក្នុងដំណើរការនៃការដេញថ្លៃ។ ក្របខ័ណ្ឌការងារសម្រាប់ការរៀបចំជំពូកគំរូរបស់សៀវភៅសិក្សា៖

### មុនចាប់ផ្ដើមសរសេរៈ

១) សូមអានឯកសារកម្មវិធីសិក្សាសម្រាប់មុខវិជ្ជា ថ្នាក់ និងប្រធានបទដោយលម្អិត

២) សូមអាន និងត្រួតពិនិត្យដោយយកចិត្តទុកដាក់លើសៀវភៅសិក្សាដែលមាន (ឯកសារយោង)

៣) ប្រមូល និងអានឯកសារទាំងឡាយណាដែលទាក់ទងនឹងប្រធានបទ

៤) សម្រេចលើគំនិត ឬព័ត៌មានសំខាន់ដែលមាននៅក្នុងកម្មវិធីសិក្សាដែលសិស្សត្រូវដឹង

៥) ធ្វើតារាងមួយអត្ថាធិប្បាយអំពីគំនិតសំខាន់ៗ និងដាក់គំនិតទាំងនេះតាមលំដាប់លំដោយសម្រាប់ការយល់ដឹងរបស់សិស្ស។៚





### ចាប់ផ្ដើមសរសេរ

៦. សរសេរសេចក្ដីផ្ដើម ពោលគឺជាវាក្យខ័ណ្ឌមួយ ដែលប្រាប់សិស្សានុសិស្សអំពីអ្វីដែលពួកគេនឹងរៀននៅក្នុងជំពូកនេះ។ ឧទាហរណ៍: ដំបូងអ្នកនឹងបានរៀនអំពី...បន្ទាប់មកអ្នកនឹងបានរៀនអំពី...។ល។

### ផ្ដល់ឯកសារជំនួយស្មារតីដំណាក់ទី១

៧) ផ្ដល់ព័ត៌មាន ឬឯកសារជំនួយស្មារតី អាចជាអត្ថបទ ឬជាដ្យាក្រាម ឬជាតារាងព័ត៌មាន ។ល។

៨) ប្រើអក្សរដិត ដើម្បីសង្កត់ធ្ងន់លើពាក្យ ឬគំនិតថ្មីសំខាន់ៗ និងត្រូវពន្យល់ពាក្យ និងគំនិតថ្មីៗទាំងនេះឱ្យបានច្បាស់លាស់

៩) រាល់ពាក្យ ឬគំនិតសំខាន់ៗនីមួយៗត្រូវបញ្ជាក់ឡើងវិញម្ដងទៀតនៅក្នុងសទ្ទានុក្រមនៅទំព័រខាងចុងបញ្ចប់នៃសៀវភៅ ។

### រួមបញ្ចូលនូវការរៀនសូត្របែបសកម្ម

១០) សរសេរសកម្មភាពទី១ ដែលតម្រូវឱ្យសិស្សប្រើប្រាស់ឯកសារជំនួយស្មារតី ឬប្រមូលព័ត៌មានបន្ថែម

១១) សកម្មភាពនេះសិស្សត្រូវមានទំនាក់ទំនងជាមួយសិស្សដទៃទៀតជាដៃគូ ឬជាក្រុមដើម្បីឱ្យពួកគេអាចរិះរកគំនិតនានា និងយល់បានកាន់តែប្រសើរ

១២) សកម្មភាពនេះតម្រូវឱ្យសិស្សប្រើប្រាស់ជំនាញនៃការគិតកម្រិតខ្ពស់ ដូចជាការយកចំណេះដឹងទៅអនុវត្តក្នុងស្ថានភាពជាក់ស្ដែង ឬវិភាគព័ត៌មាន ៚

១៣) ប្រើប្រាស់សំណួរដើម្បីជួយសិស្សឱ្យទទួលបានលទ្ធផលសិក្សាដែលយើងចង់បាន

១៤) សរសេរសកម្មភាពទី២ ដែលតម្រូវឱ្យសិស្សប្រើប្រាស់ឯកសារជំនួយស្មារតីក្នុងវិធីមួយទៀតខុសប្លែកពីអ្វីដែលមានក្នុងសកម្មភាពទី១

### ផ្តល់ឯកសារជំនួយស្មាតីជំណាក់ទី២

១៥) អនុវត្តជំហានទី៧ ទី៨ និងទី៩ ( ខាងលើ) ឡើងវិញសម្រាប់ឯកសារជំនួយស្មារតីដំណាក់កាលទី២។ ឯកសារថ្មីនេះ គួរតែស្ថិតក្នុងទម្រង់ផ្សេងខុសប្លែកពីទម្រង់ដែលប្រើសម្រាប់ដំណាក់កាលទី១ ឧទាហរណ៍ បើដំណាក់កាលទី១យើងប្រើអត្ថបទសំណេរ ដំណាក់កាលនេះយើងគួរប្រើដ្យាក្រាម

១៦) សរសេរសកម្មភាពសម្រាប់ឯកសារជំនួយស្មារតីដំណាក់កាលទី២

១៧) អនុវត្តជំហានទី១៥ ទី១៥ និងទី១៦ ឡើងវិញរហូតទាល់តែបានបង្ហាញនូវគំនិតទាំងអស់សម្រាប់ប្រធានបទត្រូវបានបង្ហាញ

### ប្រមូលគំនិតដែលបានបង្ហាញនៅជំពូក/ប្រធានបទមកដាក់រួមគ្នា

១៨) សរសេរសេចក្តីសង្ខេបមួយអំពីគោលគំនិតសំខាន់ៗដែលត្រូវបានបង្ហាញនៅក្នុងជំពូក/ប្រធានបទ។

១៩) សរសេរសំណួរត្រួតពិនិត្យឡើងវិញ ដែលតម្រូវឱ្យសិស្សបង្ហាញអំពីគំនិតសំខាន់ៗ នៅក្នុងវិធីដែលខុសប្លែកពីអ្វីដែលបានបង្ហាញនៅក្នុងអត្ថបទ។ សូមចងចាំថា យើងកំពុងតែព្យាយាមធ្វើឱ្យសិស្សយល់អំពីចំណេះដឹងថ្មី ពោលគឺមិនមែនគ្រាន់តែជារំលឹកឡើងវិញនោះឡើយ។





២០) ត្រួតពិនិត្យលើអ្វីដែលអ្នកបានសរសេរ ដើម្បីមើលអំពីភាពស៊ីសង្វាក់គ្នា និងផ្តល់សំណៅមួយច្បាប់ទៅឱ្យមិត្តរួមការងាររបស់អ្នក ដើម្បីឱ្យគាត់ជួយវាយតម្លៃប្រកបដោយការរិះគន់។ ធ្វើតេស្តអ្វីដែលអ្នកបានសរសេរជាមួយសិស្សមួយចំនួននៅក្នុងកម្រិតថ្នាក់ដែលត្រឹមត្រូវ ដើម្បីពិនិត្យមើលលើភាសា និងភាពដែលអាចអានបាន។ កែសម្រួលឡើងវិញ នៅត្រង់ណាដែលចាំបាច់។

## ៦. ការវាយតម្លៃលើសៀវភៅសិក្សា

នៅក្រោមដំណើរការ ការដេញថ្លៃដោយបឹកចំហ គណៈកម្មាធិការនឹងវាយតម្លៃទៅលើរាល់សំណើចូលរួមអភិវឌ្ឍសៀវភៅសិក្សាដែលដាក់មកដើម្បីប្រកួតប្រជែងគ្នានោះទៅលើគុណសម្បត្តិរបស់សំណើនីមួយៗ ដូចជាភាពសមស្របផ្នែកភាសា នានាភាព និងគុណភាពនៃទិដ្ឋភាពរួមក្នុងការរៀបចំទម្រង់ទំព័រ។ល។ គំរូទម្រង់បែបបទវាយតម្លៃសៀវភៅសិក្សា មាននៅក្នុងឯកសារភ្ជាប់ទី ២។

## ៧. ការសរសេរ និងការវាយតម្លៃលើសៀវភៅសិក្សាគោលសម្រាប់គ្រូ

### ៧.១ គោលបំណងនៃសៀវភៅសិក្សាគោលសម្រាប់គ្រូ

សៀវភៅសិក្សាគោលសម្រាប់គ្រូត្រូវតែផ្តល់ព័ត៌មានដែលចាំបាច់ដល់គ្រូដើម្បីអនុញ្ញាតឱ្យគ្រូអាចប្រើប្រាស់ សៀវភៅសិក្សាគោលសម្រាប់សិស្សប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។ សៀវភៅសិក្សាគោលសម្រាប់គ្រូត្រូវតែ

គោរពតាមខ្លឹមសាររបស់កម្មវិធីសិក្សា និងស្របតាមខ្លឹមសារសៀវភៅសិក្សាគោលសម្រាប់សិស្សដើម្បីជួយសម្រួលដល់គ្រូអាចយល់អំពីវត្ថុបំណងរបស់កម្មវិធីសិក្សាបាន។ សៀវភៅសិក្សាគោលសម្រាប់គ្រូគួរតែផ្ដល់យោបល់អំពីយុទ្ធសាស្ត្របង្រៀន របៀបប្រើប្រាស់អត្ថបទប្រកបដោយគុណភាពខ្ពស់ ផ្ដល់ដំណោះស្រាយចំពោះបញ្ហា ឬសំណួរដែលដាក់នៅក្នុងសៀវភៅសិក្សាគោលសម្រាប់សិស្ស និងផ្ដល់ព័ត៌មានបន្ថែមដែលដល់គ្រូ។

## ៧.២ ការសរសេរសៀវភៅសិក្សាគោលសម្រាប់គ្រូ

ការអភិវឌ្ឍសៀវភៅសិក្សាគោលសម្រាប់គ្រូត្រូវគោរពតាមគោលការណ៍សម្រាប់ការអភិវឌ្ឍសៀវភៅសិក្សាគោលសម្រាប់សិស្ស។ ប៉ុន្តែសៀវភៅសិក្សាគោលសម្រាប់គ្រូមានចំណុចបន្ថែមមួយចំនួនទៀតដែលអ្នកនិពន្ធត្រូវចងចាំដូចខាងក្រោម:

- ផ្ដល់ការពណ៌នាច្បាស់លាស់អំពីសកម្មភាពណែនាំ និងផ្ដល់នូវទិដ្ឋភាពទូទៅថាតើសកម្មភាពទាំងនេះទាក់ទងគ្នាទៅវិញទៅមក និងទាក់ទងជាមួយវត្ថុបំណងដោយរបៀបណាខ្លះ
- កំណត់នូវជំនាញដែលអ្នកសិក្សាត្រូវមានជាមុន
- ផ្ដល់នូវតារាងរាយឈ្មោះសៀវភៅអំពីប្រភពព័ត៌មាន និងឯកសារពិគ្រោះ ដែលទាក់ទងទៅនឹងប្រធានបទ
- ផ្ដល់ព័ត៌មានបន្ថែមឱ្យបានគ្រប់គ្រាន់ ដើម្បីធានាបានថាគ្រូបង្រៀនដែលមិនមែនជាអ្នកជំនាញអាចប្រើប្រាស់សៀវភៅសិក្សាគោលបានប្រកបដោយប្រសិទ្ធភាព ៚





- ផ្ដល់ព័ត៌មានលម្អិតអំពីរបៀបបង្រៀនប្រធានបទដាក់លាក់នានាដែលទាមទារនូវការប្រុងប្រយ័ត្នពិសេស ឧទាហរណ៍សុខភាពផ្លូវភេទ ជាតិពន្ធុវិទ្យា។ល។
- ផ្ដល់ការណែនាំច្បាស់លាស់ ងាយយល់អំពីការប្រើប្រាស់ឧបករណ៍ពិសេសៗណាមួយ
- គូសបញ្ជាក់អំពីបញ្ហាទាក់ទងនឹងសុវត្ថិភាពតាមការគួរ។

## ៧.៣ ការវាយតម្លៃសៀវភៅសិក្សាគោលសម្រាប់គ្រូ

ការវាយតម្លៃសៀវភៅសិក្សាគោលសម្រាប់គ្រូ ក៏ត្រូវគោរពតាមគោលការណ៍ដែលផ្ដល់ឱ្យខាងដើមស្ដីអំពីការ វាយតម្លៃលើសៀវភៅគោលសម្រាប់សិស្សដែរ។ប៉ុន្តែមានចំណុចបន្ថែមមួយចំនួនទៀតដែលអ្នកវាយតម្លៃត្រូវចងចាំដូចខាងក្រោម:

- រាល់លក្ខណៈវិនិច្ឆ័យទាំងអស់ដែលប្រើប្រាស់ដើម្បីវាយតម្លៃសៀវភៅសិក្សាគោលសម្រាប់សិស្សត្រូវយកមកអនុវត្តនៅក្នុងសៀវភៅសិក្សាគោលសម្រាប់គ្រូ
- សៀវភៅសិក្សាគោលសម្រាប់គ្រូ ផ្ដល់នូវវត្ថុបំណងច្បាស់លាស់ដើម្បីជួយសម្រួលដល់គ្រូបង្រៀនឱ្យគោរពតាមកម្មវិធីសិក្សា
- មានការពណ៌នាច្បាស់លាស់អំពីទំនាក់ទំនងរវាងប្រធានបទនានាដែលត្រូវសិក្សា
- ផ្ដល់ការឆ្លើយតបទៅនឹងសំនួរដែលត្រូវបានដាក់បញ្ចូលនៅក្នុងសៀវភៅសិក្សាគោលសម្រាប់សិស្ស ៚

- ផ្តល់ព័ត៌មានបន្ថែមឱ្យបានគ្រប់គ្រាន់ដើម្បីធានាបានថា គ្រូបង្រៀនដែលមិនមែនជាអ្នកជំនាញអាចប្រើប្រាស់សៀវភៅសិក្សាគោលសម្រាប់សិស្សបានប្រកបដោយប្រសិទ្ធភាព
- ផ្តល់នូវយុទ្ធសាស្ត្រសម្រាប់បង្រៀន ដើម្បីដោះស្រាយប្រធានបទដែលលំបាក
- ពណ៌នាអំពីឧបករណ៍/ប្រភពព័ត៌មានចាំបាច់ៗនានា
- គូសបញ្ជាក់អំពីបញ្ហាទាក់ទងនឹងសុវត្ថិភាព( ពិសោធន៍ )។





ឯកសារភ្ជាប់ទី១
ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

## សន្លឹកលក្ខណៈលំអិតរបស់សៀវភៅសិក្សាគោល

| ល.រ | អត្ថាធិប្បាយ | បញ្ជាក់ | យោបល់ |
|---|---|---|---|
| ១ | មុខវិជ្ជា | | |
| ២ | ថ្នាក់ | | |
| ៣ | ផ្តោតការយកចិត្តទុកដាក់ពិសេស | | |
| ៤ | តម្រូវការពិសេស | | |
| ៥ | កាលបរិច្ឆេទត្រូវឱ្យទៅដល់សាលា | | |
| ៦ | ចំនួនច្បាប់បោះពុម្ព | | |
| ៧ | ចំនួនទំព័រ | | |
| ៨ | ទំហំក្រដាស | | |
| ៩ | គុណភាពក្រដាស | | |
| ១០ | ប្រធានក្រុមសំណេរ | | ឈ្មោះ |
| ១១ | ប្រធានបទជំពូកគំរូ | | |
| ២៣ | អ្នកនិពន្ធ | | ឈ្មោះ |
| ១៣ | សំណៅចុងក្រោយនៃ ជំពូកគំរូ ដែលត្រូវបានអនុម័ត ដោយសមាជិកក្រុមអ្នកនិពន្ធ | ១.<br>២.<br>៣. | ឈ្មោះ និងហត្ថលេខា |
| ១៤ | ត្រួតពិនិត្យគុណភាពជំពូកគំរូ ចុងក្រោយធ្វើឡើងដោយ: | | ឈ្មោះ និងហត្ថលេខា |
| ១៥ | អនុម័តដាក់ឱ្យ ដេញថ្លៃ ដើម្បីបោះពុម្ព ដោយ: | | ឈ្មោះ និងហត្ថលេខា |

ឯកសារភ្ជាប់ទី២
ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

## ទម្រង់គំរូវាយតម្លៃ

សូមគូសរង្វង់លើប្រអប់ដែលសមស្របដែលឆ្លុះបញ្ចាំងនូវការវិនិច្ឆ័យរបស់អ្នក។

អត្រាពិន្ទុ: ១ = មិនយល់ស្របយ៉ាងខ្លាំង ..... ៥= យល់ស្របយ៉ាងខ្លាំង

ឈ្មោះសៀវភៅសិក្សាគោល........................................................

| ល.រ | អត្រាធិប្បាយ | យោបល់ | អត្រាពិន្ទុ | | | | |
|---|---|---|---|---|---|---|---|
| **ក. ខ្លឹមសារ** | | | | | | | |
| ១ | ខ្លឹមសារត្រឹមត្រូវ | | ១ | ២ | ៣ | ៤ | ៥ |
| ២ | ខ្លឹមសារស៊ីសង្វាក់គ្នាជាមួយកម្មវិធីសិក្សា | | ១ | ២ | ៣ | ៤ | ៥ |
| ៣ | លំដាប់ និងភាពស៊ីជម្រៅរបស់ប្រធានបទ សមស្រប ទៅនឹងសេចក្ដីត្រូវការរបស់អ្នកសិក្សា | | ១ | ២ | ៣ | ៤ | ៥ |
| ៤ | ខ្លឹមសារមានភាពពាក់ព័ន្ធជាមួយបរិបទប្រទេសកម្ពុជា | | ១ | ២ | ៣ | ៤ | ៥ |
| ៥ | កម្រិតនៃភាពលំបាក សមស្របសម្រាប់អ្នកសិក្សា | | ១ | ២ | ៣ | ៤ | ៥ |
| ៦ | ខ្លឹមសារបានបញ្ចូលនូវបទពិសោធន៍ក្នុងពិភពជាក់ស្ដែងដល់អ្នកសិក្សា | | ១ | ២ | ៣ | ៤ | ៥ |
| **ខ. ការណែនាំផ្នែករចនា** | | | | | | | |
| ៧ | បញ្ជាក់ច្បាស់លាស់អំពីគោលបំណង និងវត្ថុបំណង | | ១ | ២ | ៣ | ៤ | ៥ |





| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨ | សមស្របសម្រាប់វិធីសាស្ត្របង្រៀន/រៀនច្រើនបែប | | ១ | ២ | ៣ | ៤ | ៥ |
| ៩ | លើកកម្ពស់ការចូលរួមរបស់អ្នកសិក្សា | | ១ | ២ | ៣ | ៤ | ៥ |
| ១០ | លើកកម្ពស់ការរៀនបែបសកម្ម | | ១ | ២ | ៣ | ៤ | ៥ |
| ១១ | លើកកម្ពស់ជំនាញក្នុងការទាក់ទង | | ១ | ២ | ៣ | ៤ | ៥ |
| ១២ | លើកទឹកចិត្តឱ្យមានអន្តរទំនាក់ទំនងជាមួយក្រុម | | ១ | ២ | ៣ | ៤ | ៥ |
| ១៣ | លើកទឹកចិត្តចំពោះភាពច្នៃប្រឌិតរបស់អ្នកសិក្សា | | ១ | ២ | ៣ | ៤ | ៥ |
| ១៤ | អនុញ្ញាត/លើកទឹកចិត្តអ្នកសិក្សាឱ្យអាចធ្វើការដោយឯករាជ្យ | | ១ | ២ | ៣ | ៤ | ៥ |
| ១៥ | សមស្របសម្រាប់គោលបំណងដែលបានគ្រោងទុក | | ១ | ២ | ៣ | ៤ | ៥ |
| ១៦ | មេរៀនរៀបចំបានល្អ និងមានរចនាសម្ព័ន្ធ | | ១ | ២ | ៣ | ៤ | ៥ |
| ១៧ | ពន្យល់បញ្ញត្តិនានាឱ្យច្បាស់លាស់ | | ១ | ២ | ៣ | ៤ | ៥ |
| ១៨ | បញ្ញត្តិនានាត្រូវបានអភិវឌ្ឍច្បាស់លាស់ | | ១ | ២ | ៣ | ៤ | ៥ |
| ១៩ | សង្ខេបអត្ថន័យបញ្ញត្តិនានាឱ្យច្បាស់លាស់ | | ១ | ២ | ៣ | ៤ | ៥ |
| ២០ | មុខវិជ្ជានីមួយៗមានការគាំទ្រមុខវិជ្ជាដទៃទៀតក្នុងកម្មវិធី | | ១ | ២ | ៣ | ៤ | ៥ |
| ២១ | ប្រើវាក្យស័ព្ទដែលមិនមែនជាវាក្យស័ព្ទបច្ចេកទេសឱ្យសមស្រប | | ១ | ២ | ៣ | ៤ | ៥ |
| ២២ | ត្រូវណែនាំ និងពន្យល់ ពាក្យបច្ចេកទេសឱ្យមានលក្ខណៈសុសង្វាក់ | | ១ | ២ | ៣ | ៤ | ៥ |
| ២៣ | ឧទាហរណ៍អំពីឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់ | | ១ | ២ | ៣ | ៤ | ៥ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **គ. ការរចនាផ្នែកបច្ចេកទេស** | | | | | | | |
| ២៤ | អត្ថបទត្រូវមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងដ្យាក្រាម ឬតារាង។ល។ | | ១ | ២ | ៣ | ៤ | ៥ |
| ២៥ | ការរចនាជំនួយផ្នែកចក្ខុគួរឱ្យចាប់អារម្មណ៍/មានប្រសិទ្ធភាព | | ១ | ២ | ៣ | ៤ | ៥ |
| ២៦ | ឧទាហរណ៍បង្ហាញ មានប្រសិទ្ធិភាព និងសមស្រប | | ១ | ២ | ៣ | ៤ | ៥ |
| ២៧ | ទំហំអក្សរសមស្រប | | ១ | ២ | ៣ | ៤ | ៥ |
| ២៨ | រចនាបទមានលំដាប់លំដោយសមស្រប និងស៊ីសង្វាក់ | | ១ | ២ | ៣ | ៤ | ៥ |
| ២៩ | អ្នកសិក្សាអាចប្រើប្រាស់ធនធាននេះបានដោយងាយ | | ១ | ២ | ៣ | ៤ | ៥ |
| **បញ្ហាដទៃទៀត** | | | | | | | |
| ៣០ | សមភាពយេនឌ័រត្រូវបានគិតគូរដល់នៅក្នុងសៀវភៅទាំងមូល | | ១ | ២ | ៣ | ៤ | ៥ |
| ៣១ | បញ្ហាបរិស្ថាន និងនិរន្តរភាពត្រូវបានយកចិត្តទុកដាក់យ៉ាងសមស្រប | | ១ | ២ | ៣ | ៤ | ៥ |
| ៣២ | មិនមានគុណវិបត្តិអ្វីសម្រាប់អ្នកសិក្សាដែលពិការភាពក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលនេះ | | ១ | ២ | ៣ | ៤ | ៥ |
| ៣៣ | មិនមានគុណវិបត្តិអ្វីសម្រាប់ អ្នកសិក្សាមកពីក្រុមជនជាតិភាគតិច ក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលនេះ | | ១ | ២ | ៣ | ៤ | ៥ |
| យោបល់ទៅលើភាពសមស្រប: | | | | | | | |
| អនុសាសន៍: | | | | | | | |
| ឈ្មោះអ្នកវាយតម្លៃ:____________ ហត្ថលេខា:_________កាលបរិច្ឆេទ: ______ | | | | | | | |